**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Dec-2011, 13:22
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការចែកចាយដោយមិនមានការអនុញ្ញាតនូវឯកសារសម្ងាត់បំផុតទៅអ្នកពិគ្រោះយោបល់ខាងក្រៅ ដោយក្រុមមេធាវីការពារក្ដីលោក នួន ជា**

---


ដាក់ដោយ៖

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Zara LOCKSHIN
Mojan SAMADI


ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. មេធាវីការពារក្តីជនជាប់ចោទ នួន ជា (ហៅថា "មេធាវីការពារក្តី") សូមដាក់សំណើនេះ ដើម្បីឆ្លើយតបទៅនឹង "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម" (សេចក្តីសម្រេចលើសម្បទា)[1]។ ដោយសារតែនេះជាបញ្ហាបឋម មេធាវីការពារក្តី ប្រកាន់ជំហរថា សំណើនេះគួរតែចាត់ថ្នាក់ថាជាឯកសារសាធារណៈ។ គ្រប់កាលៈទេសៈទាំងអស់ មេធាវីការពារក្តី នឹងចាត់ទុកសំណើនេះថាជាឯកសារសាធារណៈ។

## II. ប្រវត្តិនីតិវិធី

២. ក្នុងការបដិសេធសំណើសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម[2] អជសដ បានចេញសេចក្តីព្រមានដូចខាងក្រោម៖

> អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារសម្ងាត់បំផុត ឬឯកសារសម្ងាត់ជាច្រើនត្រូវបានផ្តល់ឲ្យអ្នកពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រខាងក្រៅ ដែលប្រការនេះគឺធ្វើបំពានមាត្រា ៨.១ នៃសេចក្តីណែនាំស្តីពីចំណាត់ប្រភេទ និង គ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។ អនុលោមតាមវិធាន ៣៥(៥) និង ៣៨ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះព្រមានក្រុមមេធាវីការពារក្តីរបស់ នួន ជា កុំឲ្យបញ្ចេញព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតដោយគ្មានការអនុញ្ញាតតទៅទៀត[3]។

អង្គជំនុំជម្រះថែមទាំង "ណែនាំឲ្យក្រុមមេធាវីការពារក្តី នួន ជា បញ្ជាក់ថាតើឯកសារដែលត្រូវបានចាត់ថ្នាក់រួចហើយ កំពុងតែស្ថិតក្នុងដៃតតិយជន ឬយ៉ាងណា និងត្រូវរាយការណ៍ជូន

---

[1] ឯកសារលេខ **E-115/3** "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម" ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១, ERN 00750957–00750973។

[2] សូមមើលឯកសារ "សំណើសុំចាត់តាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់លោក នួន ជា ក្នុងការចូលរួមក្នុងសវនាការ" ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១, ERN 00740580–00740589។

[3] សេចក្តីសម្រេចលើសម្បទា កថាខណ្ឌ៣៩។

អង្គជំនុំជម្រះក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ ពាក់ព័ន្ធនឹងវិធានការដែលក្រុមមេធាវីការពារក្តី និងអនុវត្តក្នុងការបង្ការកុំឲ្យមានការចែកចាយ ឬបញ្ចេញឯកសារនេះ ដោយគ្មានការអនុញ្ញាតតទៅទៀត”[4]។

## III ច្បាប់ដែលពាក់ព័ន្ធ

៣. អនុលោមតាមវិធាន ៣៥(១)(ក) “អវតក អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម (ក) ផ្សាយចេញព័ត៌មានសម្ងាត់ដោយរំលោភទៅនឹងដីការបស់ [...] អង្គជំនុំជម្រះ។ នៅពេលដែលអង្គជំនុំជម្រះ “មានហេតុផលជឿជាក់ថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្ត” អំពើណាមួយ អង្គជំនុំជម្រះអាច៖ [...] (ខ) ដឹកនាំការស៊ើបសួរបន្ថែមដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី, [...]”[5]។

៤. នៅពេលដែលមេធាវីណាម្នាក់ដែលត្រូវបានទទួលស្គាល់ឲ្យបម្រើការងារនៅចំពោះមុខ អវតក “ប្រសិនបើឃើញថា បានប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុង [វិធាន៣៥(១)], [...] អង្គជំនុំជម្រះដែលរកឃើញកំហុសនោះ អាចកំណត់ថា ការប្រព្រឹត្តអំពើនេះគឺជាកំហុសវិជ្ជាជីវៈរបស់មេធាវី ដូចមានចែងក្នុងវិធាន ៣៨”[6]។ វិធាន ៣៨(១) ចែងដូចខាងក្រោម៖ “អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង”។ មាត្រា ២១ (៣) នៃកិច្ចព្រមព្រៀងតម្រូវឲ្យមេធាវីបម្រើការនៅ អវតក “ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាន និងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់”។

---

[4] សេចក្តីសម្រេចលើសម្បទា កថាខណ្ឌចុងក្រោយ ទំព័រទី១៧។

[5] វិធាន ៣៥(២)។

[6] វិធាន ៣៥(៥)។

៥. មេធាវីដែលពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន [វិធាន ៣៥] ត្រូវទទួលបានជំនួយផ្នែកច្បាប់ប្រសិនបើគាត់បំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី ដែលមានចែងនៅក្នុងវិធាន ១១"[7]។

## IV អំណះអំណាង

៦. អង្គជំនុំជម្រះហាក់ដូចជា គិតថា "មានហេតុផលដើម្បីជឿជាក់ថា [សមាជិកម្នាក់ ឬច្រើនជាងនេះនៃមេធាវីការពារក្ដី] អាចប្រព្រឹត្ត [អំពើមួយ] ក្នុងចំណោមអំពើក្នុង [វិធាន ៣៥(១)]"[8]។ ទោះបីជាយ៉ាងណាក៏ដោយ ដោយគ្មានការស៊ើបអង្កេត អង្គជំនុំជម្រះបានប្រញាប់ប្រញាល់ដាក់ទណ្ឌកម្មមកលើមេធាវីការពារក្ដីតាមរូបភាព (១) ព្រមាន "ប្រឆាំងនឹងការបង្ហាញដោយមិនមានការអនុញ្ញាតនូវព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត"[9] និង (២) ណែនាំដល់មេធាវីការពារក្ដីបង្កាកុំឲ្យមានការចែកចាយតទៅទៀត[10]។

៧. មុនពេលពឹងផ្អែកលើវិធានការដាក់ទណ្ឌកម្ម (ដោយពុំមានដំណើរការត្រឹមត្រូវ) អង្គជំនុំជម្រះគួរតែ "ដឹកនាំការស៊ើបសួរបន្ថែមដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី"[11]ដែរឬអត់។ ជាពិសេសក្នុងចំណោមបញ្ហាដទៃទៀត មេធាវីការពារក្ដីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងឲ្យស្ដាប់ចម្លើយមាជិករបស់មេធាវីការពារក្ដី ដែលនឹងរីករាយ សហការណ៍យ៉ាងពេញទំហឹងក្នុងការស៊ើបអង្កេតនេះ។

៨. ដោយពិចារណាលើភាពមធ្យ័តនៃការចោទប្រកាន់មកលើមេធាវីការពារក្ដី និងការដាក់ទណ្ឌកម្មដ៏មានសក្ដានុពល[12] អង្គជំនុំជម្រះអាចពិចារណាដល់ការចាត់តាំងមេធាវីពិសេស ដើម្បី

---

[7] វិធាន ៣៥(៣)។

[8] វិធាន ៣៥(២)។

[9] សេចក្ដីសម្រេចលើសម្បទាក ថាខណ្ឌ ៣៩។

[10] សេចក្ដីសម្រេចលើសម្បទា កថាខណ្ឌចុងក្រោយ ទំព័រទី១៧។

[11] វិធាន ៣៥(២)(ខ)។

[12] សូមមើលកថាខណ្ឌទី ៤ ខាងលើ។

ផ្តល់ប្រឹក្សាដល់បុគ្គលដែលនឹងត្រូវស៊ើបអង្កេតដោយអង្គជំនុំជម្រះ[13]។ ប្រសិនបើភាពចាំបាច់តម្រូវមានឡើង សមាជិកក្រុមមេធាវីការពារក្តីស្ម័គ្រចិត្តនឹងបង្ហាញខ្លួន។

៩. សំណើនេះចាត់ទុកជាការឆ្លើយតបជាផ្លូវការ និងពេញលេញទៅនឹងសេចក្តីសម្រេចលើសម្បទា ដែលនាំទៅដល់ការប៉ុនប៉ងមិនត្រឹមត្រូវក្នុងការ៖ (១) រារាំងដល់មេធាវីការពារក្តីក្នុងការដេញដោលលើភស្តុតាងដោយមានប្រសិទ្ធភាព, (២) រារាំងមេធាវីការពារក្តីក្នុងការការពារក្តីឲ្យបានពេញលេញ, និង (៣) បិទបាំងអង្គជំនុំជម្រះ និង សេចក្តីសម្រេចរបស់ខ្លួនពីភាគី និងសាធារណៈជន។

សហមេធាវីការពារក្តីលោក **នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[13] សូមមើលកថាខណ្ឌទី ៥ ខាងលើ។